**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Feb-2012, 15:36
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១២

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ស.ដ: សាធារណៈ/Public

ប្រភេទនៃចំណាត់:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មផ្សេងទៀត នៅក្នុងក្របខណ្ឌនៃការជំនុំជម្រះនៅដំណាក់កាលដំបូង ក្នុងសំណុំរឿង ០០២**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក គង់ សំអុន

លោក Arthur VERCKEN

លោក Jacques VERGES

**ជំនួយការ៖**

អ្នកស្រី សេង សុជាតា

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្ដារា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

| | |
|---|---|
| កញ្ញា Marie CAPOTORTO | **សហព្រះរាជអាជ្ញា៖** |
| កញ្ញា Shéhérazade BOUARFA | លោកស្រី ជា លាង |
| កញ្ញា Clémence WITT | លោក Andrew CAYLEY |
| កញ្ញា អ៊ូច ស្រីផាត | **មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| កញ្ញា Mathilde CHIFFERT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| កញ្ញា Samy SALAMON | |

## ជូនចំពោះអង្គជំនុំជម្រះសាលាដំបូង

១. កាលពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាមួយបង្គាប់ឲ្យ "បំបែកកិច្ចចោទប្រកាន់ដែលបានប្ដឹងមកខ្លួន តាមរយៈដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០២"[1]។

២. នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង "អនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការពិចារណាឡើងវិញ និងកែប្រែដីកាដំណោះស្រាយ ទៅតាមសំណើដែលបានធ្វើឡើង" ដោយសហព្រះរាជអាជ្ញា ដែលសុំឲ្យបន្ថែមទីតាំងឧក្រិដ្ឋកម្មចំនួន ៩ ទៀតទៅក្នុងការជំនុំជម្រះដំណាក់កាលដំបូងនៃសំណុំរឿង ០០២ ឬ "ផ្ដល់ឱកាសឲ្យភាគីបង្ហាញសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឬផ្ទាល់មាត់ ពីវិធីផ្សេងទៀតក្នុងការបំបែកការចោទប្រកាន់ នៅក្នុងសំណុំរឿង"[2]។

៣. បន្ទាប់ពីបានពិនិត្យចម្លើយតបរបស់ក្រុមមេធាវីការពារក្ដី លោក នួន ជា និង ក្រុមមេធាវីការពារក្ដីលោក អៀង សារី[3] អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោល<u>ទាំងស្រុង</u>នូវសំណើសុំរបស់សហព្រះរាជអាជ្ញា ក្នុងការពិចារណាឡើងវិញលើដីកាបំបែកសំណុំរឿង[4]។

---

[1] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ឯកសារ E124។

[2] សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញនូវ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ឯកសារ E124" ឯកសារ E124/2 កថាខណ្ឌ ៤៥។

[3] ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E124/5 ; ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញទៅលើ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E124/6។

[4] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានា នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារE124/7។

៤. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង បន្ថែមនូវទីតាំងចំនួន ៣ ក្នុងចំណោមទីតាំងចំនួន ៩ ដែលបានស្នើសុំពីដំបូង កាលពីថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១[5]។

៥. នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ លោក អៀង សារី បានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើរបស់សហព្រះរាជអាជ្ញា ដោយមូលហេតុថា នេះគឺជាការព្យាយាមសាជាថ្មីរបស់សហព្រះរាជអាជ្ញា ក្នុងការស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ពិចារណាឡើងវិញលើដីកាបំបែកសំណុំរឿង[6]។

៦. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅ លោក អៀង សារី ដោយបានបង្ហាញថា "គ្មានក្រុមមេធាវីការពារក្តីផ្សេងបានដាក់ចម្លើយតបជូនអង្គជំនុំជម្រះទេ"[7]។ លោក ខៀវ សំផន សូមរំលឹកសហព្រះរាជអាជ្ញា ថា មាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក បានផ្តល់រយៈពេលកំណត់ចំនួន ១០ ថ្ងៃ "គិតពីថ្ងៃជូនដំណឹងនៃឯកសារដែលត្រូវឆ្លើយតប"។ សំណើរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងនាថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២[8]។ ដូច្នេះ ភាគីមានរយៈពេលឆ្លើយតបរហូតដល់ថ្ងៃច័ន្ទ ទី ១៣ ខែ កុម្ភៈ។

**ភាពមិនអាចទទួលយកបាននៃសំណើរបស់សហព្រះរាជអាជ្ញា**

---

[5] សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/១ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ (ជូនដំណឹងដល់ភាគីនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២) ឯកសារ E163។

[6] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះលើរឿងក្តី ០០២/១ ឯកសារ E163/1។

[7] ការសុំការអនុញ្ញាតរបស់សហប្រហារាជអាជ្ញា ដើម្បីឆ្លើយតប និងការឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី ទាក់ទិននឹងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/១ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E163/2, កថាខណ្ឌ ២។

[8] សូមមើលឧបសម្ព័ន្ធ។

៧. លោក ខៀវ សំផន យល់ថា សំណើរបស់សហព្រះរាជអាជ្ញាមានលក្ខណៈច្រំដែល។ សហព្រះរាជអាជ្ញាលើកឡើងដដែលៗនូវសំណើមុនៗរបស់ខ្លួន ដោយធ្វើការបង្រួម[9]។ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបដិសេធទាំងស្រុង[10] នូវសំណើពីមុនរបស់សហព្រះរាជអាជ្ញារួចហើយនោះ លោក ខៀវ សំផន នឹងមិនឆ្លើយតបទៅនឹងខ្លឹមសារនៃសំណើថ្មីនេះឡើយ និងស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលសំណើរបស់សហព្រះរាជអាជ្ញា ដោយមិនចាំបាច់ធ្វើការពិចារណាបន្ថែមទៀតឡើយ។

## យោងតាមសំអាងហេតុខាងលើ

៨. ក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន ស្នើអង្គជំនុំជម្រះសាលាដំបូង៖

**បដិសេធ**សំណើរបស់សហព្រះរាជអាជ្ញា ដោយមិនចាំបាច់ធ្វើការពិចារណាបន្ថែមទៀតឡើយ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ភ្នំពេញ<br><br>ប៉ារីស<br><br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

[9] ឯកសារ E163 កថាខណ្ឌ ៥ “ដូច្នេះ សហព្រះរាជអាជ្ញា ស្នើសុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មចំនួន ៣ ប៉ុណ្ណោះ ក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មទាំង ៩ កន្លែង ដែលបានស្នើពីដំបូងដោយសហព្រះរាជអាជ្ញា ដើម្បីដាក់បញ្ចូលទៅក្នុងសវនាការដំបូងនេះ នៅក្នុងសំណើរឿង ០០២”។

[10] ឯកសារ E124/7។